**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
លេខ ៧៤០ ពណ.ចបព.ប្រក

ភ្នំពេញថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ ២០១៧

# ប្រកាស
## ស្តីពី
## ការបង្កើតបញ្ជរតែមួយលើការងារចុះបញ្ជីពាណិជ្ជកម្ម
## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ ២០៨MOC/SM២០០៧ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម របស់ក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ ២២២MOC/SM ២០១២ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១២ របស់ក្រសួងពាណិជ្ជកម្មស្តីពីការចុះបញ្ជីនាមករណ៍សហគ្រាសក្រុមហ៊ុន ឈ្មោះសមាគម និងកិច្ចការពារ
- បានឃើញប្រកាសលេខ ០៦៣MOC/SM ២០១៣ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីនីតិវិធីរួមនៃការផ្តល់សេវាដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្ម
- យោងប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់ក្នុងទិសដៅកែទម្រង់ការងារ ចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ដើម្បីសម្រួលដល់វិស័យឯកជន និងគោលបំណងកិច្ចសម្រួលពាណិជ្ជកម្មដោយកាត់បន្ថយបែបបទ

# សម្រេច

**ប្រការ ១៖**

ត្រូវបានបង្កើត បញ្ជរតែមួយ ចំពោះរាល់ការងារចុះឈ្មោះសហគ្រាសក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម។ រាល់ការស្នើសុំចុះឈ្មោះ សហគ្រាស ក្រុមហ៊ុន ក្នុងបញ្ជីពាណិជ្ជកម្ម និងការពិនិត្យឈ្មោះសហគ្រាស ក្រុមហ៊ុន អ្នកស្នើសុំត្រូវចូលមកបញ្ជរចុះបញ្ជីពាណិជ្ជកម្មដើម្បីផ្ទៀងផ្ទាត់ និងសុំការអនុញ្ញាតប្រើនាមករណ៍ សហគ្រាស ក្រុមហ៊ុន ។

**ប្រការ ២៖**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣៖**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា ប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ប្រធានអង្គភាពនានាចំណុះក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ស៊ុន ចាន់ថុល**

**ចម្លងជូន:**

- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- សាលារាជធានីខេត្ត
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ